## ការប្រើប្រាស់ជីៈ

ការប្រើប្រាស់ជីតាមបច្ចេកទេស នឹងនាំឱ្យទទួលបានទិន្នផលខ្ពស់ ព្រមទាំងគុណភាពផ្លែល្អ។ កម្រិតជីដែលអាចប្រើប្រាស់គឺ ៧៥ : ៣០ :១០០ គ.ក្រ/ហ.ត នៃ N : $P_2O_5$ : $K_2O$ ។ ការប្រើប្រាស់ជីអាចលើសពីនេះ អាស្រ័យទៅតាមកម្រិតជីជាតិរបស់ដី។ ការបាចជីអាចចែកជាបីលើក គឺទ្រាប់បាតមុនដាំ (៥០%) បំប៉នលើកទីមួយពេលចេញផ្កា ២៥% និងបំប៉នលើកទីពីរក្រោយប្រមូលផលលើកទីមួយ ២៥% នៃជីទាំងបីប្រភេទ។

## ការប្រមូលផល

នៅពេលផ្លែចាប់ផ្តើមប្រែទៅពណ៌ក្រហមបាន ១០% - ២០% ឬនៅរយៈពេល ២០ -២៥ ថ្ងៃក្រោយចេញផ្លែគេអាចធ្វើការប្រមូលផលបាន។ ការប្រមូលផលនៅដំណាក់កាលនេះ គឺអាចជួយកាត់បន្ថយការខូចខាតពេលដឹកជញ្ជូនបានមួយចំណែក និងអាចរក្សាទុកផ្លែបានច្រើនថ្ងៃ។



## ការទុកដាក់ក្រោយពេលប្រមូលផល

ការបាត់បង់ក្រោយពេលប្រមូលផល អាចបណ្តាលមកពីកត្តាពីរ គឺទីមួយការបម្រែបម្រួលសារធាតុចិញ្ចឹមក្នុងផ្លែ និងទីពីរការខូចខាតដោយការប៉ះទង្គិច។ ដើម្បីជៀសវាងការបាត់បង់នេះ កសិករគួរធ្វើការប្រមូលផលទុកដាក់ និងដឹកជញ្ជូនឱ្យបានសមស្រប និងជាពិសេសត្រូវរើសផ្លែដែលខូចដូចជាស្អុយ មានជម្ងឺ មានសត្វល្អិតបំផ្លាញ ជាំ ឬប្រេះ ដាក់ដាច់ដោយឡែកពីផ្លែដែលល្អ។





រៀបចំដោយ មជ្ឈមណ្ឌលរុក្ខជម្រើសវិទ្យា

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)




# ពូជប៉េងប៉ោះ នាងពេជ្រ

## Neang Pich



វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Cambodian Agricultural Research and Development Institute

## ប្រវត្តិរបស់ពូជ

ពូជប៉េងប៉ោះ " **នាងពេជ្រ** "ត្រូវបានរំដោះដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជានាចុងឆ្នាំ ២០០៦ បន្ទាប់ពីបានធ្វើការពិសោធន៍រយៈពេលប្រាំមួយរដូវ (បីឆ្នាំ) កន្លងមក។ ពូជនេះមានប្រភពដើមចេញពីស្រឡាយ CLN2498A របស់មជ្ឈមណ្ឌលអាស៊ីស្តីពីការស្រាវជ្រាវ និងអភិវឌ្ឍន៍ដំណាំបន្លែ (AVRDC) ។

## លក្ខណៈពិសេសៗរបស់ពូជ " នាងពេជ្រ "

### ការលូតលាស់

ពូជ " **នាងពេជ្រ** " ជាពូជលូតលាស់មានកំណត់ បានន័យថា ក្រោយការប្រមូលផល ដើមរបស់វានឹងងាប់។ ពូជនេះមានកំពស់ចាប់ពី ៦០ ស.ម ទៅ ១០០ ស.ម ដែលចាប់ចេញផ្កានៅរយៈពេល ៥៥ ថ្ងៃ ចេញផ្លែនៅរយៈពេល ៦២ ថ្ងៃ និងចាប់ផ្តើមទុំនៅរយៈពេល ៨៥ ថ្ងៃ ក្រោយថ្ងៃដុះ។ គេអាចធ្វើការប្រមូលផលចំនួនពីរលើក ដោយលើកទីមួយអាចចាប់ផ្តើមនៅរយៈពេល ២០-២៥ ថ្ងៃក្រោយចេញផ្លែ និងលើកទីពីរនៅរយៈពេលមួយសប្តាហ៍ ឬពីរសប្តាហ៍ក្រោយប្រមូលផលលើកទីមួយ។

### ភាពធន់នឹងកំដៅ

ជាទូទៅកសិករធ្វើការដាំដុះដំណាំប៉េងប៉ោះចាប់ពីរដូវទឹកសម្រក ឬរដូវរំហើយ (តុលា -មករា) តែសម្រាប់ការដាំដុះក្នុងរដូវក្តៅ (កុម្ភៈ-ឧសភា) តែងតែជួបប្រទះនូវការខូចខាត ដែលបណ្តាលមកពីអាកាសធាតុក្តៅខ្លាំងធ្វើឱ្យដំណាំជ្រុះផ្កា និងអត្រាដាក់ផ្លែទាប។ ដោយឡែកពូជ " **នាងពេជ្រ** " អាចដាំដុះបានទាំងនៅរដូវទឹកសម្រក និងនៅរដូវក្តៅ។ ការធន់នឹងកំដៅនេះអាចដោយសារពូជនេះមានឫសច្រើន ហើយចាក់ចូលជ្រៅទៅក្នុងដី។

### ភាពធន់នឹងជម្ងឺ

ពូជប៉េងប៉ោះ " **នាងពេជ្រ** " មានភាពធន់ទ្រាំទៅនឹងជម្ងឺវីរុសលឿងរួញស្លឹក ដែលជាជម្ងឺធ្ងន់ធ្ងរមួយដល់ដំណាំប៉េងប៉ោះ។

### ការទុកគ្រាប់ដាំបន្ត

ពូជប៉េងប៉ោះ " **នាងពេជ្រ** " ជាពូជដែលអាចរក្សាគ្រាប់ពូជទុកដាំដុះនៅរដូវបន្តបន្ទាប់ទៀតបាន មិនដូចជាពូជអ៊ីប្រ៊ីដទេ។

### ទិន្នផល

ទិន្នផលរបស់ពូជ " **នាងពេជ្រ** " អាចខ្ពស់ជាងទិន្នផលរបស់ពូជអ៊ីប្រ៊ីដមួយចំនួនដែលកសិករទិញពីផ្សារ។ ក្នុងរដូវក្តៅ បានផលជាមធ្យម ១៩ តោនក្នុងមួយហិកតា ឯក្នុងរដូវរំហើយ បានរហូតដល់ ៣០ តោនក្នុងមួយហិកតា។

### លក្ខណៈផ្លែ

ផ្លែមានរាងពងក្រពើ មានទម្ងន់ជាមធ្យម ៥៥ ក្រាម។ នៅពេលខ្ចីផ្លែមានពណ៌បៃតង និងមានពណ៌ក្រហមនាពេលទុំ។ សាច់ខាងក្នុងពណ៌លឿងទុំ។ នាពេលទុំ ផ្លែប៉េងប៉ោះពូជនេះមានរសជាតិឆ្ងាញ់។ មានកម្រាស់សាច់មធ្យមដែលអាចធន់ទ្រាំនឹងការប្រេះផ្លែ សមស្របសម្រាប់ការហូបជាបន្លែស្រស់ដូចជាធ្វើឡុកឡាក់ជាដើម និងមានបរិមាណសារធាតុខនិជចិញ្ចឹមប្រមាណ ៥,៥% ។ ផ្លែដែលស្រគាលអាចរក្សាទុកបានដល់ ១២ ថ្ងៃ ក្នុងសីតុណ្ហភាពធម្មតា ។



## វិធីសាស្ត្រដាំដុះ

កូនប៉េងប៉ោះត្រូវបណ្តុះនៅលើកន្ទោងរហូតដល់អាយុបាន ២០ ទៅ ៣០ ថ្ងៃទើបយកទៅដាំ។ ចន្លោះពីដើមមួយទៅដើមមួយគឺ ៥០ ស.ម និងចន្លោះជួរគឺ ១០០ ស.ម។ រងដំណាំមានទទឹង ១ ម បណ្តោយ ៥ ម និងកំពស់ ២០ ស.ម។ ចំពោះការដាំដុះក្នុងរដូវវស្សា (ឧសភា-សីហា) ទាមទារឱ្យមានការលើករងកំពស់ ២៥-៣០ ស.ម ហើយប្រសិនបើអាចគ្របរងដោយគម្របចំបើង ឬផ្លាស្ទិចរឹតតែប្រសើរ។ នៅពេលដំណាំចាប់ចេញកញ្ចុំផ្កា (ប្រមាណពីរសប្តាហ៍ក្រោយដាំ) ត្រូវចាប់ផ្តើមដោតទ្រើង ឬចំណារដើម្បីទប់ដើម និងចង្កោមផ្លែកុំឱ្យបាក់នៅពេលផ្លែរបស់វារីកធំ។ ក្នុងផ្ទៃដីមួយហិកតា គេត្រូវការគ្រាប់ពូជប្រមាណ ២០០ ក្រាម ទៅ ៣០០ ក្រាម សម្រាប់ចន្លោះគុម្ពដូចខាងលើ។ ក្នុងផ្លែមួយចង្កោមគួរទុកត្រឹម ៤-៥ ផ្លែដើម្បីឱ្យផ្លែធំល្អ និងក្នុងមួយដើមគួរទុក ៥-៦ ចង្កោម បើមានដើមបែកច្រើនយើងគួរធ្វើកាត់វាចោលខ្លះ ។







